# តើអ្នកស្គាល់ច្បាប់នៃការឈប់សម្រាកដោយមានប្រាក់ឈ្នួលឬទេ?

**ការឈប់សម្រាកដោយមានប្រាក់ឈ្នួលជាអ្វី?**

ដើម្បីអោយការបណ្តុះបណ្តាលប្រកបដោយសុវត្ថិភាពនឹងសុខមាលភាព វាជាកាចាំបាច់ណាស់ក្នុងការស្តាថាមពល ដែលបាត់បង់ នៅពេលបំពេញការងារប្រចាំថ្ងៃ ព្រមទាំងការធ្វើអោយមានតុល្យភាព រវាងការងារ និងជីវភាពប្រចាំថ្ងៃ។ ដោយឡែក ពីថ្ងៃ ឈប់សម្រាកជាទៀតទាត់ ច្បាប់នៃការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលគឺជាច្បាប់ដែលអនុញ្ញាតអោយអ្នកឈប់សម្រាកនៅថ្ងៃធ្វើការ ហើយប្រាក់ខែក៏នៅតែទទួលបានក្នុងកំឡុងពេលសម្រាកនោះដែរ។ ការឈប់សម្រាកដោយទទួលបានប្រាក់ខែ ហៅថា ゆうきゅうきゅうか។ ចំនួនថ្ងៃឈប់សំរាកដោយមានប្រាក់ឈ្នួលដែលសិក្ខាកាមនឹងទទួលបាន គឺត្រូវបានកំណត់ដោយច្បាប់មានដូចខាងក្រោម៖ ក្រោយពីបញ្ចប់ការសិក្សានៅប្រទេសជប៉ុន គិតរាប់ចាប់ពីថ្ងៃ ចូលធ្វើជាសិក្ខាកាមបណ្តុះបណ្តាលជំនាញ ក្នុងរយៈពេល៦ខែដំបូង ក្នុងករណីដែលបានធ្វើការ លើសពី៨០%ឡើងទៅ អ្នកទាំង អស់គ្នានឹងមានសិទ្ធិទទួលបានថ្ងៃឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ចំនួន១០ថ្ងៃ។ បន្ទាប់ពីនោះមក នៅពេលអ្នកបន្តធ្វើការបានរហូតដល់ ១ឆ្នាំនិង៦ខែ អ្នកនឹងមានសិទ្ធិទទួលបានថ្ងៃឈប់សម្រាកដោយមានប្រាក់ឈ្នួល ចំនួន១១ថ្ងៃ។ នៅពេលឈានដល់ ២ឆ្នាំ៦ខែ អ្នកនឹងទទួលបាន១២ថ្ងៃ។ នៅពេលឈានដល់៣ឆ្នាំ៦ខែ អ្នកនឹងទទួលបាន១៤ថ្ងៃ ហើយនៅពេលឈានដល់៤ឆ្នាំ៦ខែ អ្នកនឹងទទួលបាន១៦ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះថ្ងៃឈប់សំរាកដែលអាចទទួលបាន សិក្ខាកាម ត្រូវធ្វើការអោយបានយ៉ាងហោចណាស់៨០%នៃថ្ងៃធ្វើការ ដែលបានកំណត់សម្រាប់រយៈពេល១ឆ្នាំ

**តើប្រើប្រាស់ថ្ងៃឈប់សម្រាកដោយមានប្រាក់ឈ្នួលដោយរបៀបណា?**

ត្រូវដាក់ពាក្យស្នើសុំទៅក្រុមហ៊ុនដោយខ្លួនឯងថា«ខ្ញុំចង់ឈប់សម្រាក់ដោយមានប្រាក់ឈ្នួលនៅថ្ងៃទី.... ខែ....»។ របៀបនៃការដាក់ពាក្យស្នើសុំ គឺខុសគ្នាទៅតាមក្រុមហ៊ុននីមួយៗ។ ចំពោះរបៀបនៃការដាក់ពាក្យស្នើសុំ គឺត្រូវបានសរសេរនៅក្នុងលក្ខខណ្ឌការងារនិងច្បាប់ការងាររបស់ក្រុមហ៊ុនរបស់សិក្ខាកាម។ អ្នកអាចសាកសួរទៅកាន់ប្រធានក្រុមហ៊ុនឬ សិស្សច្បង។

**ច្បាប់ថ្មីនឹងត្រូវបានបន្ថែមចាប់ពីថ្ងៃទី០១ខែ០៤**

ចំពោះកម្មករនិយោជិតដែលមានថ្ងៃឈប់សម្រាកដោយមានប្រាក់ឈ្នួលលើសពី១០ថ្ងៃ ក្រុមហ៊ុនត្រូវអនុញ្ញាតិអោយឈប់អោយបានយ៉ាងហោចណាស់៥ថ្ងៃជារៀងរាល់ឆ្នាំ។ ចំណែកឯ កម្មករនិយោជិតដែលបានប្រើថ្ងៃឈប់សម្រាកដោយមានប្រាក់ឈ្នួលចំនួន៥ថ្ងៃរួចហើយ មិនត្រូវបានអនុញ្ញាតទេ។

**ចំណុចកត់សម្គាល់**

ការឈប់សម្រាកដោយមានប្រាក់ឈ្នួល គឺជាគោលការណ៍មួយដែលការឈប់សម្រាកអាចទទួលបាននៅថ្ងៃដែលបានស្នើសុំ។ ប៉ុន្តែ ក្នុងករណី នៅថ្ងៃដែលអ្នកបានស្នើរសុំឈប់វាមានការបញ្ហារប៉ះពាល់ កើតឡើងដល់ក្រុមហ៊ុននោះ ក្រុមហ៊ុននឹងប្តូរថ្ងៃឈប់សម្រាក់ទៅថ្ងៃផ្សេង។ មុនពេលដាក់ពាក្យស្នើរសុំឈប់សម្រាកដោយមានប្រាក់ឈ្នួល សូមពិភាក្សាជាមួយប្រធានក្រុមហ៊ុន ឬសិស្សច្បង។ ហើយអ្នកត្រូវមានផែនការច្បាស់លាស់ក្នុងការឈប់ដើម្បីកុំអោយលើសចំនួនថ្ងៃដែលគេផ្តល់អោយ។




វាគឺជាការប្រគួតដ៏ល្អមែន! ការផ្លាស់ប្តូរវប្បធម៌របស់សិក្ខាកាមនៃតំបន់ Kansai (ប្រទិសជប៉ុនភាគខាងលិច) នៅថ្ងៃទី24 ខែ2 នៅកីឡាដ្ឋាន(ហ្វុសាល)

## បទសម្ភាសន៍ជាមួយអ្នកប្រឡងជាប់សមត្ថភាពភាសាជប៉ុន

【អ្នកប្រឡងជាប់N3 នៅខែ១២ ឆ្នាំ២០១៨ 】
លោក BUI VAN NAM,
និងលោក NGUYEN THANH TUAN
(ក្រុមហ៊ុន: YUUSEI／ការចងដែក・ចងដែកថ្នឹម)

### ការព្យាយាមគង់បានសម្រេច



(ពីខាងឆ្វេងដៃ) លោក TUAN, លោក NAM

លោក NAM និងលោក TUAN គាត់បានមកប្រទេសជប៉ុននៅខែមករា ឆ្នាំ២០១៨ ក្នុងនាមជាសិក្ខាកាមហ្វឹកហាត់ជំនាញបច្ចេកទេស។ កាលពីឆ្នាំមុននៅខែធ្នូពួកគាត់ទាំង២នាក់បានប្រឡងជាប់ចំណេះដឹងភាសាជប៉ុនកម្រិតN3។ ពួកគាត់ទាំង២នាក់នៅបន្ទាប់ពីចេញពីធ្វើការត្រឡប់ទៅផ្ទះវិញពួកគាត់ងូតទឹក ញ៉ាំបាយហើយគឺចាប់ផ្តើមរៀនភាសាជប៉ុន។ សម្រាប់លោក NAM នៅថ្ងៃដែលមានការងារធ្វើគឺគាត់រៀនចាប់ពីម៉ោង៨យប់ដល់១២យប់។ លោក NAMគាត់ប្រើសៀវភៅ『新完全マスター単語 日本語能力試験 N3 重要 1800 語』និងសៀវភៅ『日本語総まとめ N3 漢字』ដើម្បីធ្វើជាឯកសារជំនួញដល់ការសិក្សា។ ដើម្បីអោយងាយស្រួលដល់ការចងចាំអក្សរកាន់ជិ និងពាក្យគាត់បានប្រើកាតពាក្យ (ក្រដាស់កាតពាក្យ) ដើម្បីសិក្សារ។ចំណែកលោកTUANវិញគឺគាត់រៀនភាសាជប៉ុនកម្រិតN3តាម YouTube។ ពួកគាត់ទាំង២នាក់តែងតែមើលភាយន្ត និងស្តាប់ចំរៀងជាភាសាជប៉ុនតាមទូរទស្សន៍ និងតាមវេបសាយ។ លោក TUAN វិញគាត់ចូលចិត្តធ្វើត្រាប់តាមតារាសម្តែង ក្រុមAKB48ពីព្រោះគាត់ជាអ្នកគាំទ្រ ។ ផ្សេងពីនេះទៀតលោក NAM ក្នុង១ខែពីរដងនៅថ្ងៃអាទិត្យលោកតែងតែបានមករៀន ភាសារជប៉ុននិងភាសារវៀតណាម ។ វាបានផ្លាស់អារម្មណ៍យ៉ាងល្អសំរាប់លោកNAM ដោយសារតែមានតំណើរកំសាន្តតាមសាលានិងការធ្វើBBQ (ញ៉ាំសាច់អាំង) ជុំគ្នាជាដើមនោះ។ហើយលោកNAMបានអោយពាក្យមួយឃ្លាដល់អ្នកដែលមានបំណងប្រឡងយកN3ថា "ការខំប្រឹងដោយមិនបោះបង់ដល់ចុងក្រោយគឺជារឿងចំបាច់" ។ ចំណែកលោក TUANក៏មានពាក្យមួយឃ្លាដែរថា "ការតស៊ូគង់បានសម្រេច" ។

# INFORMATION

**ពិធីបុណ្យខ្មែរឆ្នាំ២០១៩**

វាជាព្រឹត្តការណ៍ដើម្បីរំលែកចំណងប្រទេសជប៉ុននិងកម្ពុជា !
កាលបរិច្ឆេទ(ថ្ងៃសុក្រ) ទី៣ ខែ៥ និង (ថ្ងៃសៅរ៍) ទី៤
ចាប់ពីម៉ោង ១០:០០ រហូតដល់ ១៩:០០
ទីកន្លែង : នៅសួន Yoyogi Park (តូក្យូ)
ឧបត្ថម្ភដោយគណៈកម្មាធិការប្រតិបត្តិកម្ពុជាឆ្នាំ 2019
http://www.cambodiafestival.com/index.html

**ទៅកាន់មិត្តសិក្ខាកាមបណ្តុះបណ្តាលជំនាញ**

យើងខ្ញុំនឹងណែនាំទស្សនាវដ្តីដែលមានសរសេរជាភាសាខ្មែរ និងភាសាជប៉ុនសម្រាប់អ្នកចេះខ្លះៗ អំពីពត៌មានសំខាន់ៗនៃជីវភាពរស់នៅរបស់សិក្ខាកាមបណ្តុះបណ្តាលជំនាយ។
អាចចូលអានដោយឥតគិតថ្លៃពីវេបសាយនេះ https://www.jitco.or.jp/ja/tomo/